**1ST QUARTER BULLETIN NOVEMBER 2025-APRIL 2026**

# NEWSLETTER

**PROJECT: IMPROVEMENT OF HEALTH CONDITIONS AND EDUCATIONAL OPPORTUNITIES AT SCHOOLS IN NORTHERN CAMBODIA THROUGH EDUCATION ON PUBERTY AND SEXUALITY.**

## 1 OVERVIEW & IN COLLABORATION

The project aims to improve health and educational opportunities for students in Preah Vihear Province. Supported by BMZ through KHA and Engagement Global, and implemented by RainWater Cambodia in partnership with the Ministry of Education, Youth and Sport, the initiative focuses on five districts: Chey Saen, Chhaeb, Kuleaen, Choam Ksant, and Sangkum Thmei. Project Period: 24 months (November 2025 – October 2027).





## 2 PROJECT INTRODUCTION AND LAUNCHING

RainWater Cambodia in collaboration with the Preah Vihear Provincial Department of Education, Youth and Sport (PoEYS), organized a workshop to officially launch the project: "Improvement of health conditions and educational opportunities at schools in northern Cambodia through education on puberty and sexuality."

The workshop was presided over by Ms. Kim Kunthearin, Deputy Director of the Preah Vihear Provincial Department of Education, Youth and Sport.



## 3 SCHOOL MAPPING & ASSESSMENT

We conducted school targeted mapping and on-site evaluations of WASH facilities to verify quality and functionality ensuring that all water, sanitation, and hygiene installations align with the national standards and guidelines set by the Ministry of Education, Youth and Sport. By mapping these locations, we have created a clear baseline to ensure project resources are allocated effectively and infrastructure improvements are prioritized where they are needed most.





## 4 TRAINING OF TRAINERS

From January 13 to 15, 2026, RainWater Cambodia, in collaboration with the Provincial Department of Education, Youth, and Sport, organized a Training of Trainers (TOT) on "Menstrual Health and Hygiene (MHM), Puberty, and Sexual Education." The program aims to promote the well-being and rights of adolescent girls in schools with a total of 22 participants (9 females)

## 5 TRAINING OF TRAINERS ( SFP AND SMC )



In collaboration with the Provincial Department of Education, Youth and Sport (PoEYS), we successfully organized a Training of Trainers (ToT) for School Health focal points and School Management Committees. The training focused on Menstrual Hygiene Management (MHM) and Puberty Education, covering five target districts: Kulen, Chey Sen, Chhaeb, Sangkum Thmei, and Choam Ksant. with a total of 377 participants (including 142 women).

Mr. MAO YAO

School Management Committee

Mr. Mao Yao, Chairman of the Khjong Primary and Secondary Schools Management Committee, expressed deep concern regarding cases of girls as young as 13-14 years old becoming pregnant and starting families at such an early age.



📢 **To all parents and youth: "Please do not rush into starting a family during your school years. Prioritize your health and strive for academic excellence to build a strong and secure future first!"**

## 6 MH KITS DISTRIBUTION

In March, the project team successfully executed the first phase of MH kits distribution mission to all targeted schools in Kulen, Chey Sen , Sangkum Thmei, Chhaeb and Chaom Ksant. In total 1,644 kits.





## 7 COMMUNE DIALOGUE

Commune dialogue was successfully held in 2 commune in Kulen and 1 commune in Sangkum Thmei focusing on "Menstrual Hygiene, Puberty, and Sexual Education."

The dialogue featured three key sessions:

- Session 1: Menstrual Hygiene & Puberty
- Session 2: Reproductive and Sexual Health
- Session 3: Digital Safety & Parenting Skills

## 8 PROJECT WORKING GROUP MEETING

On March 25, 2026, we hosted a productive stakeholder dialogue meeting focused on improving health and education for students in Northern Cambodia!
With 20 representatives from Provincial and District Education offices and local government in attendance, we shared our latest progress on puberty and sexuality education. Our discussions led to three clear goals for the next phase:
✅ Making commune-level dialogues even more effective.
✅ Improving "safety boxes" in schools to better support students.
✅ Ensuring every girl receives her menstrual hygiene kits on time, every time.



Address: Lor It village, Kampong Pranak commune, Preah Vihear province

Email: rainwatercambodia@online.com.kh

Tel: +855 71 4111 327

ត្រីមាសទី ១ខែវិច្ឆិកា ២០២៥ ដល់ខែមេសា ២០២៦

# ព្រឹត្តិបត្រព័ត៌មាន

**គម្រោង៖ ការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌសុខភាព និងឱកាសអប់រំនៅសាលារៀន ភាគខាងជើងនៃប្រទេសកម្ពុជា តាមរយៈការអប់រំអំពីភាពពេញវ័យ និងផ្លូវភេទ**

## 1 ទិដ្ឋភាពទូទៅ និងកិច្ចសហប្រតិបត្តិការ



គម្រោង ការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌសុខភាព និងឱកាសអប់រំនៅសាលារៀន ភាគខាងជើងនៃប្រទេសកម្ពុជា តាមរយៈការអប់រំអំពីភាពពេញវ័យ និងផ្លូវភេទ។ គោលបំណងលើកកម្ពស់សុខភាព និងឱកាសសិក្សាដល់សិស្សានុសិស្សក្នុងខេត្តព្រះវិហារ។ គាំទ្រថវិកាដោយ BMZ តាមរយៈ KHA និង Engagement Global និងអនុវត្តដោយ អង្គការទឹកភ្លៀងកម្ពុជា ក្នុងភាពជាដៃគូជាមួយក្រសួងអប់រំ យុវជន និងកីឡា គំនិតផ្តួចផ្តើមនេះផ្តោតលើស្រុកចំនួន ៥៖ ជ័យសែន ស្រុកឆែប គូលែន ជាំក្សាន្ត និងសង្គមថ្មី ។ គម្រោងនេះមានរយៈពេល ២៤ខែ (ចាប់ពីខែវិច្ឆិកា ឆ្នាំ២០២៥ ដល់ខែតុលា ឆ្នាំ២០២៧)។

## 2 សិក្ខាសាលាប្រកាសដាក់ឱ្យដំណើរការគម្រោង

អង្គការទឹកភ្លៀងកម្ពុជា សហការជាមួយមន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រះវិហារ បានរៀបចំសិក្ខាសាលាប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនូវគម្រោង៖ “ ការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌសុខភាព និងឱកាសអប់រំនៅសាលារៀន ភាគខាងជើងនៃប្រទេសកម្ពុជា តាមរយៈការអប់រំអំពីភាពពេញវ័យ និងផ្លូវភេទ ” ដែលបានប្រព្រឹត្តទៅក្រោមអធិបតីភាព លោកស្រី គឹម គន្ធារីន អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះវិហារ។



## 3 ការរៀបចំផែនទី និងវាយតម្លៃសាលារៀន

ក្រុមការងាររបស់អង្គការទឹកភ្លៀងកម្ពុជា បានដៅផែនទីតាមគោលដៅរបស់សាលា និងវាយតម្លៃសម្ភារៈបរិក្ខារ WASH ដើម្បីផ្ទៀងផ្ទាត់គុណភាព និងមុខងារធានាថារាល់ការដំឡើងទឹកស្អាត និងអនាម័យ ស្របតាមស្តង់ដារជាតិ និងគោលការណ៍ណែនាំដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។ តាមរយៈការដៅផែនទី ទីតាំងទាំងនេះ យើងបានបង្កើតមូលដ្ឋានច្បាស់លាស់មួយ ដើម្បីធានាថា ធនធានគម្រោងត្រូវបានបែងចែកប្រកបដោយប្រសិទ្ធភាព។



## 4 វគ្គបណ្តុះបណ្តាលគ្រូបង្គោល



ថ្ងៃទី ១៣ ដល់ថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០២៦ អង្គការទឹកភ្លៀងកម្ពុជា បានសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ ស្តីពី "សុខភាពនិងអនាម័យពេលមករដូវ (MHM) ភាពពេញវ័យ និងការអប់រំផ្លូវភេទ"។ វគ្គបណ្តុះបណ្តាលនេះ មានគោលបំណង លើកកម្ពស់សុខុមាលភាព និងសិទ្ធិរបស់ក្មេងស្រីជំទង់នៅក្នុងសាលារៀន ដែលមានអ្នកចូលរួមសរុបចំនួន ២២ នាក់ (ស្រី ៩ នាក់)។

## 5 សិក្ខាសាលាបណ្តុះបណ្តាលគ្រូសុខភាពសិក្សា និងគណៈកម្មការគ្រប់គ្រងសាលា



ក្រោមកិច្ចសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះវិហារ អង្គការទឹកភ្លៀងកម្ពុជា បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោល ជូនដល់គ្រូបង្គោលសុខភាពសិក្សា និងគណៈកម្មការគ្រប់គ្រងសាលារៀន ប្រកបដោយជោគជ័យ។ វគ្គបណ្តុះបណ្តាលនេះ បានផ្តោតសំខាន់លើ "ការគ្រប់គ្រងអនាម័យពេលមករដូវ (MHM)" និង "ការអប់រំអំពីភាពពេញវ័យ" ដែលបានប្រព្រឹត្តទៅនៅក្នុងស្រុកគោលដៅចំនួន៥ រួមមាន៖ ស្រុកគូលែន ជ័យសែន ឆែប សង្គមថ្មី និងស្រុកជាំក្សាន្ត ដោយមានអ្នកចូលរួមសរុបចំនួន ៣៧៧ នាក់ (ក្នុងនោះមានស្ត្រីចំនួន ១៤២នាក់)។

**លោក ម៉ៅ យ៉ោ**

គណៈកម្មការគ្រប់គ្រងសាលាបឋម/អនុវិទ្យាល័យខ្យង

លោក ម៉ៅ យ៉ោ ប្រធានគណៈកម្មការគ្រប់គ្រងសាលាបឋមសិក្សានិងអនុវិទ្យាល័យខ្យង បានបង្ហាញការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះករណីក្មេងស្រីអាយុត្រឹម ១៣-១៤ ឆ្នាំ មានផ្ទៃពោះ និងយកគ្រួសារទាំងវ័យក្មេង។



📢 សារដាស់តឿនពីលោក......គណៈកម្មការ៖ «សូមអាណាព្យាបាល និងក្មួយៗយុវតីទាំងអស់ កុំប្រញាប់យកគ្រួសារក្នុងវ័យសិក្សា។ ត្រូវរក្សាសុខភាពឱ្យមាំមួន និងខិតខំរៀនសូត្រឱ្យខ្ពង់ខ្ពស់ ដើម្បីកសាងអនាគតឱ្យរឹងមាំជាមុនសិន!»

## 6 ការចែកចាយឈុតកំណាត់អនាម័យរដូវ

ក្នុងខែមីនា-ខែមេសា ឆ្នាំ២០២៦ ក្រុមការងារគម្រោង បានចុះផ្តល់ជូននូវ សម្ភារៈអនាម័យពេលមក រដូវលើកទី១ ដល់សាលារៀនគោលដៅទាំងអស់នៅគូលែន ជ័យសែន សង្គមថ្មី ឆែប និងជាំក្សាន្ត។ សរុបចំនួន ១៦៤៤ឈុត។



## 7 កិច្ចប្រជុំសំវាទថ្នាក់ឃុំ



កិច្ចប្រជុំសំវាទថ្នាក់ឃុំ បានរៀបចំឡើងចំនួន ៤ឃុំ នៅស្រុកគូលែនចំនួន៣ និងនៅស្រុកសង្គមថ្មី ចំនួន ១ឃុំ ផ្តោតលើ "អនាម័យពេលមករដូវ ភាពពេញវ័យ និងការអប់រំផ្លូវភេទ"។

កិច្ចប្រជុំសំវាទនេះផ្តោតលើកិច្ចពិភាក្សាសំខាន់ៗចំនួនបី៖

១. អនាម័យមករដូវ និង ភាពពេញវ័យ

២. ការអប់រំវ័យពេញវ័យ (សុខភាពបន្តពូជ និងសុខភាពផ្លូវភេទ

៣. សុវត្ថិភាពឌីជីថល និងបំណិនមាតាបិតា

## 8 កិច្ចប្រជុំក្រុមការងារគម្រោង

នៅថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០២៦ អ.ទ.ក បានរៀបចំកិច្ចប្រជុំពិភាក្សាជាមួយភាគីពាក់ព័ន្ធយ៉ាងរលូន ដើម្បីផ្តោតលើគម្រោង ការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាព និងឱកាសអប់រំរបស់សិស្សានុសិស្សនៅភាគខាងជើងប្រទេសកម្ពុជា។ តាមរយៈការចូលរួមពីតំណាងមន្ទីរអប់រំ និងអជ្ញាធរមូលដ្ឋានសរុបចំនួន ២០នាក់ ក្នុងនោះបានធ្វើបច្ចុប្បន្នភាពគម្រោង ស្តីពីការអប់រំអំពីភាពពេញវ័យ និងការអប់រំផ្លូវភេទ។ កិច្ចពិភាក្សាក្នុងអង្គប្រជុំបានសម្រេចនូវគោលដៅច្បាស់លាស់ចំនួន ៣ សម្រាប់ដំណាក់កាលបន្ទាប់៖

✅ បន្តរៀបចំ និងពង្រឹងកិច្ចប្រជុំពិភាក្សាថ្នាក់ឃុំឱ្យកាន់តែមានប្រសិទ្ធភាព។

✅ កែលម្អ "ប្រអប់សុវត្ថិភាព" នៅតាមសាលារៀន ដើម្បីគាំទ្រសិស្សានុសិស្សឱ្យកាន់តែប្រសើរឡើង។

✅ ធានាឱ្យបាននូវការផ្តល់ជូនសម្ភារៈអនាម័យមករដូវដល់សិស្សស្រីគ្រប់រូបឱ្យបានទៀងទាត់ និងគ្រប់ពេលវេលា។



អាសយដ្ឋាន៖ ភូមិឡឥដ្ឋ ឃុំកំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ

អ៊ីម៉ែល៖ rainwatercambodia@online.com.kh

ទូរស័ព្ទ៖ ០៧១ ៤១១ ១ ៣២៧